Khmer Story Lovers

— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៥ ផ្លូវលេខ ២៨៩ ជីឡូត៍លេខ ២៩៥ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

## ប្រលោមលោករចេញផ្សាយរៀងរាល់ថ្ងៃ



ស៊ុំផលានង៍ក់ក្បាលថ្លែងអំណរគុណ :

– បាទ, សុំអរគុណលោកម្ចាស់ ដែលជួយដាស់តឿនខ្ញុំឲ្យភ្ញាក់ខ្លួនបន្តិច ។

ម្ចាស់កោះត្រកួលឡេងកាន់ដៃមាណពពោលបន្តតថា:

–គួរស្តាយ ដោយរូបខ្ញុំនិងប្អូនប្រុស មិនបានមើលទឹកចិត្តអង់អាចក្លាហានរបស់លោកប្អូន ។

ម្ចាស់កោះត្រកួលមុខគមានចេញរាងជាម៉េចម៉ែន តែគាត់សម្លឹងមុខស៊ុំផលានង៍ មុខស្រស់ ត គួរឲ្យអាណិតណាស់ ។

ឯមាណពបានសម្រេចចិត្តថា :

– លោកម្ចាស់ទាំងពីរពេបកានស្រឡាញ់យើង ដោយស្មោះមែន, ចាំត្រឡប់ទៅជួបគាស៊ុំវិញ យើងនាំគ្នាមកលេងនឹងគាត់ម្តង ។

ម្ចាស់កោះត្រកួលឡេងផ្តាំមាណពសព្វគ្រប់ហើយ ទើបដើរទៅកន្លែងដើរវិញប្រកាសប្រាប់ភ្ញៀវទាំងអស់ថា:

– មិត្តគុននិយមជាទីមេត្រី, យើងមាននិស្ស័យនឹងគ្នា ទើបជួបជុំគ្នាលើកោះនេះ ។ ថ្ងៃវេលាដល់ពេលយើងអស់និស្ស័យនឹងគ្នាហើយ ព្រោះថ្ងៃនេះយើងត្រូវបែកគ្នារហូត ។

ភ្ញៀវទាំងឡាយឮម្ចាស់កោះពោលពាក្យចម្លែកដូច្នេះ ក៏នាំគ្នា

អ្នកប្រែសម្រួល អ.គឹមសាន

តម្លៃ ៣០៛០០

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
« មាតុភូមិ »
ភ្នំពេញ

លេខ ៤៧

ភ្ញាក់ផ្អើលសាកសួរទ្រហឹងអឺងកង :

- ហេតុអ្វី?

- លោកម្ចាស់កោះមានធុរៈ ឬ?

- លោកម្ចាស់គិតឃើញបែបណាវិញ ?

ខណៈនោះគេឮសម្លេងគ្រាំ ៗ លាន់ពីចម្ងាយដូចផ្គរលាន់រំពងលាយ ។ ទាំងអស់គ្នាសម្ងំស្ងៀមចាំស្តាប់ក្រែងមានហេតុការណ៍ប្រែប្រួលដោយថាហេតុ ។

ម្ចាស់កោះត្រកូលឡុងបន្តវាចា :

- យើងបានជួបជុំលើកោះនេះ ដើម្បីដោះស្រាយពាក្យពេចន៍នៃកំណាព្យបុរាណ ។ ប៉ុន្តែគួរស្តាយណាស់ ដោយហេតុកោះឡុងមុយើងនេះត្រូវរលំរលាយក្នុងសមុទ្រឥឡូវហើយ ។

ភ្ញៀវទាំងអស់ស្រែកសួរទ្រហឹងម្តងទៀត :

ហេតុអី ? រញ្ជួយព្រះធរណីឬ ? ភ្នំភ្លើងផ្ទុះឬ ? ហេតុអីលោកម្ចាស់ជ្រាបរឿងនេះមុន ? .

ម្ចាស់កោះរង់ចាំឲ្យមានការស្ងប់ស្ងាត់ឡើងវិញ ទើបឆ្លើយ:

- អម្បាញ់មិញ, ខ្ញុំនិងប្អូនមុបានរកឃើញមាត់ភ្នំភ្លើងនៅកណ្តាលកោះមែន ហើយភ្នំភ្លើងហ្នឹងត្រូវផ្ទុះក្នុងពេលបន្តិចទៀតធ្វើឲ្យកោះឡុងមុក្លាយជាសមុទ្រភ្លើង ហើយលិចបាត់ក្នុងមហាសាគរ ។ ឯសម្លេងគ្រាំ ៗ អម្បាញ់មិញជាសញ្ញាប្រកាសអាសន្នហើយ, សូមអស់លោកស្រូតរូតចាកចេញដំណើរពីទីនេះឆាប់ ៗ ទៅ ។

ភ្ញៀវទាំងអស់ជឿខ្លះមិនជឿខ្លះ មិនទាន់សម្រេចចិត្តយ៉ាងណាឡើយ ។ ជនភាគច្រើនស្តាយស្រណោះក្បួនយុទ្ធសិល្បៈក្នុងបន្ទប់ថ្ម មិនព្រមចាកចេញទៅស្រុកទេសវិញទេ សុខចិត្តស្លាប់រស់ជាមួយគម្ពីរបុរាណ ។ ប៉ុន្តែម្ចាស់កោះពោលបន្ត :

-បើអស់លោកមិនជឿ សុំអញ្ជើញទៅមើលផ្ទាល់ភ្នែកចុះ, បន្ទប់ថ្មទាំងប្រាំបួនបាក់បែករលំខ្ទេចខ្ទីអស់ទៅហើយ, ទោះភ្នំភ្លើងមិនទាន់ឆេះក៏អស់លោកនៅទីនេះឥតបានប្រយោជន៍អីដែរ ។

កាលបើបានឮថាបន្ទប់ថ្មរលំរលាយអស់ទើបភ្ញៀវគ្រប់រូបស្ទុះស្ទាចេញពីបន្ទប់ ។ ស៊ីជធានរត់តាមគេទៅមើលបន្ទប់ថ្ម ឃើញវិនាសហិនហោចបាត់ស្រមោលគំនូរនិងកំណាព្យបុរាណមែន ។ មាណពយល់ច្បាស់ថានេះជាស្នាដៃសិស្សកោះឡុងមុពិតប្រាកដណាស់ ទើបសោកស្តាយជាខ្លាំងនឹកថា :

Khmer Story Lovers



– លោកម្ចាស់កោះប្រើសិស្សឲ្យបំផ្លាញបន្ទប់ថ្មដោយសារយើងមើលគំនូរយល់ទេតើ !

ភ្ញៀវឯទៀតឃើញជាក់ជាស្នាដៃមនុស្ស ក៏ស្រែកឡូឡា នាំគ្នារត់ឈ្លូងមកកាន់បន្ទប់គិត្តិយសវិញ ដើម្បីសាកសួរម្ចាស់កោះ ។

ស្រាប់តែឮសម្លេងថ្ងូរញសោកទ្រហឹងពេញបន្ទប់ ។ គេនាំគ្នាចូលទៅឃើញលោកម្ចាស់កោះទាំងពីរនាក់បងប្អូនអង្គុយពែនភ្នែនបិទភ្នែកជិតឈឹង, ពពួកសិស្សក្រាបក្បាលទ្រហោយំជុំវិញគាត់ . . .

សុីផានភ័យលើសគេ, ទំរែតផ្លូវទៅជិតម្ចាស់កោះស្រែកសួរ :

–លោកម្ចាស់កើតអីហ្នឹង ?

លោកតាទាំងពីរធ្វើមុខស្មើ, នាយលូកដៃស្ទាបទ្រូងទើបដឹងថាគាត់លែងដកដង្ហើមទៅហើយ ។ នាយងាកសួរតាន់សានភ្លាម:

– លោកម្ចាស់ទាំងពីរមានសុខភាពបរិបូណ៌សោះម៉េចក៏អនិច្ចកម្មទទេ ៗ អ៊ីចឹង ?

តាន់សានងិងលីសែយំខ្សឹកខ្សួល :

– អម្បាញ់មិញ . . . លោកគ្រូមានប្រសាសន៍ថាគោលបំណងគាត់បានសម្រេចហើយ, គាត់អាចបិទភ្នែកជិត ហុី . . . ហុី ... លោកគ្រូស្លាប់ចោលយើងហើយ !

សុីផានលំបាកចិត្តណាស់ទ្រាំមិនបាន ក៏យំខឹងគេដែរ មួយស្របក់ធំទើបសិស្សច្បងពាក់អាវលឿនជូតទឹកភ្នែកស្អាតក្រោកឈរពោលក្តែង ៗ:

– សូមជំរាបអស់លោកជាទីគោរពថា លោកគ្រូយើងខ្ញុំបែកស្ពានទៅហើយ , មុននឹងដាច់ខ្យល់លោកបានផ្តាំឲ្យអស់លោកអញ្ជើញទៅស្រុកទេសយ៉ាងប្រញាប់ ។ រឿងកបញ្ហាសូមអស់លោកគ្រាទុកឲ្យគង់ , បើថ្ងៃក្រោយមានបញ្ហាពិបាកដោះស្រាយ , សូមកាន់ផ្កាកស្ពាន់ទៅរកយើងខ្ញុំនៅភូមិនេសាទមួយតាមច្រាំងសមុទ្រណាំហៃ ។

អ្នកក្លាហានទាំងអស់កំពុងលោកស្តាយម្ចាស់កោះ ព្រមទាំងក្បួនយុទ្ធសិល្ប:ដ៏វិសេសមិនទាន់បាត់ផង , កាលបើពួកសិស្សគណខាងកោះឡុងមុផ្តាំផ្ញើយ៉ាងនេះ គេធូរទ្រូងបន្តិច ព្រោះកោះឡុងមុមានតិរិវិជ្ជាខ្ពង់ខ្ពស់ណាស់ ទោះមានការលំបាកយ៉ាងណា ក៏គេអាចជួយបានខ្លះដែរ ។

បន្ទាប់ពីនោះសិស្សច្បងពាក់អាវខៀវពោល :

– យើងខ្ញុំបានរៀបចំទូករួចហើយ, សូមអស់លោកអញ្ជើញ !

–អ្នកក្លាហានរាល់រូបសំដែងមរណទុក្ខចំពោះសពលោកម្ចាស់កោះ, ចាន់សាននិងលីសើកាន់ដៃ ស៊ីផធានផ្ដាំថា :

–ប្អូនពៅទៅឲ្យបានសុខណា៎ ! បើថ្ងៃក្រោយមានពេលទំនេរបងទៅលេងនឹងប្អូនមិនខាន ៗ

មាណពលាបងធម៌ទាំងពីរ ដោយអាឡោះអាល័យនិងក្រៀមក្រំ ទើបដើរតាមប៉ាយជីចាយ និងអ្នកក្លាហានស្រុកលាវគុងទៅកាន់មាត់សមុទ្រ ដែលមានទូកតូចធំក្រៀបត្រា ៗ ភ្ញៀវណាដែលបានមករស់លើកោះម្កុ ឬសាមសិបឆ្នាំចុះទូកទាំងអាឡោះអាល័យ, រីភ្ញៀវដែលទើបមកដល់ថ្មី ១ ឡើងទូកដោយសប្បាយរីករាយ ៗ ទូកតូចធំបើកក្ដោងចាកចេញទៅ រហូតមើលមកកោះឃើញតូចលឹមៗ...

ស៊ីផធាននឹកឃើញរឿងមួយស្រាប់តែទន្ទ្រាំជើងស្រែក :

– លោកតា, វីវរហើយ ! ថ្ងៃនេះប៉ុន្មានកើត, ខែអី ?

ប៉ាយជីចាយស្រែកយ៉ូយ ! និយាយញ័រមាត់:

– តាមិន...ដឹងដែរ...ថ្ងៃនេះប៉ុន្មានកើត ?

ទីងមិនហួសប្អូនអង្គុយកៀនជញ្ជាំងទូកពោលចំអក:

– ប្រហែលប្អូន, ប្រាំបួនឬដប់កើតហើយអីង ?

ស៊ីផធានងាកខ្វាប់សួរ:

– លោកតាទីង, លោកតាចាំដែរ, យើងមកកោះនេះប៉ុន្មានថ្ងៃហើយ ?

– ហ៊ឺ ! ចិតសិបថ្ងៃក៏ដោយ, ប៉ែតសិបថ្ងៃក៏ដោយ គ្មាននរណាអង្គុយតែចាំសព្វគ្រប់ទេ !

ស៊ីផធានអន្ទះអន្ទែងខ្លាំងឡើងងាកសួរលោកស្រីកាវសានលាងជីទៀត :

– លោកមីង, យើងមកដល់កោះតាំងពីថ្ងៃប្រាំបីកើតខែកត្ដិក, ឥឡូវថ្ងៃនេះប៉ុន្មានកើតខែមិគសិរ?

លោកស្រីរាប់ម្រាមដៃគិតមួយសន្ទុះ ទើបឆ្លើយ:

– យើងមកដល់កោះឡុងមុបានហាសិបប្រាំពីរថ្ងៃហើយ , ថ្ងៃនេះបើមិនប្រាំមួយកើត ក៏ប្រាំពីរកើតខែបុស្សដែរ ...

ប៉ាយជីចាយនិងស៊ីផធានស្រែកភ្ញាក់សម្ញេង:

– ស្អី ? ចូលដល់ខែបុស្សហើយ ?

– ចាសពិតជាខែបុស្សមែន ៗ

ប៉ាយជីតាយលើកដៃគក់ទ្រូងឌឹប ៗ . . .

ទីងមិនហួសប្អូនសើចហាស ៗ:

– សប្បាយណាស់អញ ! ហាស ៗ ! . . . សប្បាយ ...

ស៊ុផឆានស្រែកទាំងឈឺចាប់ :

– លោកតាទីង ! លោកយាយខ្ញុំថាដល់ថ្ងៃប្រាំបីកើតខែមិគសិរ, បើមិនឃើញពួកខ្ញុំត្រឡប់ទៅវិញ, គាត់លោតទឹកសម្លាប់ខ្លួនហើយ ! អាស៊ីវ ... ក៏ដូច្នោះដែរ, ហេតុអីតាសប្បាយ ?

ទីងមិនហួសប្អូនស្រឡាំងកាំង :

– អូ, គាត់ថាលោតទឹកសម្លាប់ខ្លួននៅថ្ងៃប្រាំបីកើតខែមិគសិរឬ ? ឥឡូវចូលខែបុស្សហើយតើ !

ស៊ុផឆានអត់ទ្រាំមិនបានក៏ស្រែកយំហ៊ូ:

– ធ្វើម៉េចទៅ ? ហ៊ុ ... ហ៊ុ...

ទីងមិនហួសប្អូនសង្កៀតធ្មេញ:

– អាឈ្លួយថាសម្លាប់ខ្លួននៅថ្ងៃប្រាំបីកើតខែមិគសិរ,ត្រូវស្លាប់ហួសមកជាងម្ភៃថ្ងៃហើយគ្មានធ្វើម៉េចកើតទេ ៗ អាឈ្លួយចិត្តដាច់ណាស់. តែគេចង់ស្លាប់គេមិនបង្អង់មួយថ្ងៃឬពីរថ្ងៃឡើយ នៃប៉ាយជីតាយរបល់យក៍, ម៉េចមិនត្រឡប់ទៅវិញឲ្យទាន់ពេលកញ្ចាស់ចង្រៃយក៍ !

ប៉ាយជីតាយគក់ទ្រូងផ្ទូង ៗ ស្រែកតប:

– មែន ! មែនហើយ ! យើងចង្រៃណាស់, សូមរបល់មកយកឆាប់ ៗ ទៅ !

ទីងមិនហួសប្អូនស្រែកជេរថែម :

– អាឆ្កួតតពូផងពោកៈស្លាប់ឆាប់ទៅ ! ម៉េចឯងមិនប្រញាប់អូសជើងកញ្ចាស់នេះទៅវិញឲ្យទាន់ពេល ?

ស៊ុផឆានឆ្លើយទាំងឈឺចាប់ :

– ត្រូវហើយ ! ខ្ញុំមិនរស់ទេ, លោកតាជេរខ្ញុំត្រូវណាស់ ៗ

ខណៈនោះស្រាប់តែពុស្ត្រីម្នាក់ស្រែកគ្រលួច :

–ស៊ីសាវឈ្លួយស្លាប់ក៏ស្លាប់ទៅ, គ្មានទើសក្បាលកញ្ចាស់ឯងទេ, ម៉េចហ៊ានជេរស្ដីគេយ៉ាងហ្នឹង ?

នេះជាសម្លេងស្ត្រីបិទមុខត្រកូលម៉ី ៗ ទីងមិនហួសប្អូនលែងស្រែកដូចមុន តែនៅរអ៊ូម្នាក់

Khmer Story Lovers

ឯង, ប៉ាយជីតាយបន្ទោសស៊ុឺផាន :

– បើឯងដឹងអីចឹងដែរ ម៉េចមិនប្រាប់តាផង ?

ស៊ុឺផានមានការណឺចាប់ឥតឧបមាមិនឆ្លើយប្រាប់តាប៉ាយឡើយ ។

ទូកក្ដោងជក់ខ្យល់អណ្ដែតលឿនលយតម្រង់ដីគោក ... ប៉ាយជីតាយបន្ទោសស៊ុឺផានចប់តាមផ្លូវ ទីនមិនហួសបួនស្ដីបន្ទោសចុះឡើងញុះញង់តាប៉ាយកើនរឿងវាយតប់គ្នា តែបានអ្នកក្លាហានក្បែរនោះឃាត់ ។

ថ្ងៃទីបី , ពេលព្រលប់គេអាចមើលឃើញដីគោកលឹម ៗ ។ អ្នកក្លាហានទាំងអស់ស្រែកហ៊ោកញ្ជៀវសំដែងសេចក្ដីរីករាយ ។ ប៉ាយជីតាយក្រោកឈរសម្លឹងទឹកសមុទ្រហាក់ចង់រាវរកឃាយស៊ុនិងអាស៊ីវ , ស៊ុឺផានសម្លឹងពីលើទូកឃើញប្រាំងសមុទ្រនៅជងដែលទេសភាពមាក់ទឹកឥតផ្លាស់ប្ដូរ ... នាយនឹកដល់ពេលកាន់ដៃអាស៊ីវហៀបចុះទូកតូច , នឹកដល់សំដីឃាយស៊ុផ្ដាំផ្ញើ នឹកសំដីអាស៊ីវ... ឥឡូវនាយត្រឡប់មកវិញតាមពាក្យសន្យា តែអ្នកគ្រូនិងអាស៊ីវនៅឯណា ? ក្លាយជាចំណីត្រីឯមច្ឆាអស់ហើយឬ ?

មាណពស្រវេះស្រវោចពេកក្រៃស្រក់ទឹកភ្នែកព្រោកៗស្រវាំងភ្នែកមើលទេសភាពលែងច្បាស់ ។

ទូកខិតជិតដល់ប្រាំងស្រាប់តែឮសម្រែកកងរំពងផ្សាយពីកំពូលភ្នំក្បែរមាត់ប្រាំង ។ គេនាំគ្នាក្រឡេកមើលទៅឃើញស្រមោលពីរខ្មៅមួយសមួយលោតចុះទឹកសមុទ្រ ។

ស៊ុឺផានមានភ្នែកមុតមើលស្គាល់ជាក់ជាឃាយស៊ុនិងអាស៊ីវពិតប្រាកដ ។ មាណពរំភើបចិត្តពន់ពេកឥតបានគិតថាហេតុអ្វីឃាយស៊ុនិងអាស៊ីវមិនទាន់ស្លាប់ទេ ។ នាយស្រវាបានក្ដារមួយបន្ទះចោលវិលតម្រង់កន្លែងដែលស្ដ្រីទាំងពីរប្រុងធ្លាក់មក ។ បន្ទាប់ពីនោះនាយកន្ត្រាក់ជើងលោតវឹងរហ័សដូចផ្លេកព្រួញ ជិតធ្លាក់ដល់ទឹកហើយស្រាប់តែនាយប្រមូលកម្លាំងថែមទៀតហក់មួយវឹបដល់ក្ដារជាន់ជាប់ល្មមពេលដែលរាងកាយអាស៊ីវជ្រុះមកដល់ ។ នាយលូកដៃទ្រូងឱបចង្កេះនាងជាប់ ។ ក្ដារមួយបន្ទះទ្រទ្រង់កាយអ្នកទាំងពីរមិនបានក៏លិចស្រឹមក្នុងផ្ទៃសមុទ្រ ។ ក្នុងពេលជាបន្ទាន់នោះឃាយស៊ុធ្លាក់មកទៀតយ៉ាងរហ័សដូចផ្លេកបន្ទោរ ។ មាណពមិនអាចចាប់ជូនចាស់បានក៏យារដៃទះបញ្ជូនកម្លាំងតាមស្នៀតគុនលើកញ្ចាំងថ្ងឲ្យឃាយស៊ុទៅធ្លាក់លើទូកធំវិញ ។

អ្នកក្លាហានទាំងអស់ស្រែកហ៊ោកងរំពងកោតសរសើរស្នាដៃមាណព ។ ប៉ាយជីតាយនិងទីង

មិនហួសបួនស្ទុះព្រមគ្នាចាំទទួលយាយស៊ី ។ ទីនមិនហួសបួនលូកដៃទៅមុខ, ប៉ាយជីចាយស្រែកសន្ធាប់ថាចៀសចេញ !

ព្រមទាំងយារដៃម្ខាងទះគូរបដិបក្ខផង ។ ទីនមិនហួសបួនប្រុងទះសងវិញស្រាប់តែអ្នកមីយារដៃទះវ៉ូតម្រង់ទៅ ! ទីនមិនហួសបួនខ្ទាតផ្ងោងធ្លាក់ក្អឹកក្អុក ។

ពេលនោះប៉ាយជីចាយទទួលយាយស៊ីផល់ដៃដែរ, តែកម្លាំងកាយស៊ីផានច្រើនលើសលុបពេកទះដងកាយដួនចាស់បញ្ជូនមកយ៉ាងលឿនហួសវិស័យ ទាល់តែប៉ាយជីចាយចប់មិនជាប់ស្រុតក្ដារទូកប្រាវផ្លូលបះជើងប្រួង ។ តាចាស់ឱបយាយស៊ីក្នុងវង្វង់ដៃជាប់ ។

ស៊ីផានបានអាស៊ីវក្នុងកណ្ដាប់ដៃ ហើយក៏សម្រាលខ្លួនឈរលើបន្ទះក្ដារកាយទឹកមកវកខ្លួនវិញ ។ ទីនមិនហួសបួនចេះហែលបន្តិចបន្តួចដែរក៏ខំប្រវេប្រវាឡើងទូកវិញព្រមទាំងស្រែកជេរប្រមាថផ្ដេះផង ។ គេម្នាក់ខ្សែប្រឹងឲ្យតាចាស់យោងឡើងវិញហើយគេដើរដកគ្នាចេញប៉ាង ។ តាទីនទទឹកខោអាវជោកឈរសម្លឹងស្រីបិទមុខមួយសន្ទុះធំទើបស្រែកឡូឡា :

— ឯង... ឯងមិនមែនប្អូនស្រីទេ ឯង... គឺឯង !

ស្រីបិទមុខគ្រហឹមហ៊ឹះ ៗ ពោលដោយសម្លេងតឹង :

— ឯងចិត្តធំដល់ម៉្លឹងហ្ន៎ ! ហ៊ានឱបស៊ីសាវឈ្មួយនៅមុខយើងផង ! ហ៊ឹះ!

ទីនមិនហួសបួនស្រែកគោកគាក :

—ឯងគឺឯងមែន ! ស្នៀតដែលឯងប្រាថ្នាយើងទម្លាក់ទឹកអម្បាញ់មិញគ្មាននរណាចេះក្រៅពីឯងទេ !

ស្ត្រីពោលចំអក :

— អើ, ដឹងខ្លួនអីចឹងក៏ស្រួលដែរ ។

ពោលហើយអ្នកមីចាប់បកកំណាត់ខ្មៅចេញបង្ហាញផ្ទៃមុខជ្រីវជ្រួញលឿងស្លាំង ដោយខ្វះពន្លឺថ្ងៃ ទីនមិនហួសបួនឧទានទាំងរំភើបញាប់ញ័រ :

—រ៉ុនសាំង ... រ៉ុនសាំង ! ពិតជារូបអូនមែន ! ម៉េច ... អូនកុហកបងថាស្លាប់ ?

ស្ត្រីបិទមុខឈ្មោះមីរ៉ុនសាំងជាសង្សារចាស់ ដែលទីនមិនហួសបួនបំភ្លេចចោលដើម្បីទៅលួចស្រឡាញ់ស៊ីសាវឈ្មួយ ។ អ្នកទាំងពីរផុតស្មានបានជួបគ្នាក្នុងពេលនេះសោះ ។ មីរ៉ុនសាំងលូកដៃមួលត្រចៀកទីនមិនហួសបួនស្រែកដំឆាល :

- ឯងបន់ឲ្យយើងស្លាប់ដើម្បីឯងមានថ្មី ឬ ? ឥឡូវឯងសប្បាយទេ ?

តាទីងអៀនខ្មាសណាស់ តែមិនហ៊ានរើបម្រះទេ ។ គាត់ស្រែកបន្ទោសតិច ៗ :

- លែងដៃចេញ ! ធ្វើដូច្នេះមិនខ្មាសគេទេ ឬ ? មនុស្សគគោក !

ម៉ុនសាំងស្រែកទៀត :

- យើងចង់ឲ្យគេមើលឯងហ្នឹងណា ! កូនហួនតូនៅឯណា ឆាប់នាំវាមកសងយើងភ្លាម !

- ហ៊ឺ ! លែងត្រចៀកយើងសិនទៅ, ម្ចាស់កោះឡ្សងមុបានប្រាប់ថាវានៅកំពូលភ្នំត្រចៀកខ្លាឃ្មុំហើយតើ ! ចាំយើងទៅរក ។

- ហ្នឹងហើយ, រកកូនឲ្យឃើញទើបយើងលែង, បើពុំនោះសោតខ្ញុំមួលត្រចៀកគាត់ឯងទាល់តែដាច់ !

ពេលនោះទូកបានចូលចតមាត់ច្រាំងដែលមានប៉ាយវ៉ាន់ដាននិងសិស្សក្ដីទឹកកកចាំទទួលរហ័ស ៗ ទាំងអស់គ្នាឃើញប៉ាយជីតាយនិងស៊ុំផានវិលត្រឡប់មកវិញដោយសុខសាន្ត ព្រមទាំងយាយស៊ី អាស៊ីវតាកផុតពីក្ដីស្លាប់ទៀត, គេត្រេកអររកអ្វីប្រៀបផ្ទឹមពុំបាន ។ ឈាំងជីសេ, ឈីជីមានងិន លាងជីជិនអស់សង្ឃឹមរលីងតែខំសំដែងស្វាគមន៍ទទួលអ្នកដំណើរដូចគេដែរ ។ ប៉ាយវ៉ាន់ដានពោលមុនគេ :

- ពុកអើយ, ម៉ែមានប្រសាសន៍ថា ដល់ថ្ងៃប្រាំបីកើតខែមិគសិរមិនឃើញពុកត្រឡប់មកគាត់លោតទឹកសម្លាប់ខ្លួនហើយ ។ ថ្ងៃនេះប្រាំបីកើត, ខ្ញុំភ័យណាស់ខំឃាត់ឃាំងម៉ែស្រាប់តែម៉ែចុចជីពចរ ខ្ញុំរត់ទៅណាបាត់ ។ សាធុ ! សាធុ ! ទៅ...បើពុកយឺតបន្តិចទៀតច្បាស់ជាខានឃើញមុខម៉ែហើយ ។

ប៉ាយជីតាយសួរដោយឆ្ងល់:

- ថាម៉េច ? ថ្ងៃនេះទើបនឹងប្រាំបីកើត ? ខែអី ?

- បាទ, ប្រាំបីកើតខែមិគសិរ ។

- មែនឬ ?

ប៉ាយវ៉ាន់ដានងក់ក្បាលឆ្លើយបញ្ជាក់ :

- បាទពុក ។

ប៉ាយជីតាយអេះក្បាលពោលរអ៊ូរ :

- យើងទៅកោះឡ្សងមុតាំងពីថ្ងៃ ប្រាំបីកើតខែកត្តិក, យើងនៅលើកោះផាងហាសិបថ្ងៃម៉េចឥឡូវ... ទើបនឹងប្រាំបីកើតខែមិគសិរ ?

–អូ, ពុកភ្លេចហើយ? គេលើកខែណា!

ប៉ាយជីចាយលាន់មាត់ឮ! ហើយស្ទុះទៅស្រវាឱបស៊ីផាន:

– អាចៅប្រុស, ម៉េចឯងមិនប្រាប់តាផង, លើកខែអីចឹងបានជាយើងមកទាន់!

មាណពធ្វើក្បាលងីងើ:

– ស្អីទៅដែលហៅលើកខែ? ម៉េចបានខែកត្តិកដល់ទៅពីរដងក្នុងមួយឆ្នាំ?

– ហាសៗ... អាចៅ, កុំរវល់ច្រើន! លើកខែក៏ដោយមិនលើកក៏ដោយ, ឲ្យតែប្រពន្ធនៅរស់ ហាសៗ...

ទាំងអស់គ្នាសើចគិល, ស្រាប់តែប៉ាយជីចាយស្រែកសួរ:

– យីកញ្ចាស់ទីងទៅណាបាត់?

យាយស៊ុតប:

– ឯងរកគេធ្វើអី? ម៉ឺរុនសាំងញ៉ឹងស្ទីកត្រចៀកគេទៅរកកូនស្រីឈ្មោះម៉ីហួងគួបាត់ហើយ!

ស៊ីឈីន និងរុនយូពុឈ្មោះម៉ីហួងគួក៏ប្រែទឹកមុខ ហើយសួរព្រមគ្នាភ្លាម:

– លោកអ៊ំ, គេទៅរកម៉ីហួងគួកន្លែងណា?

យាយស៊ុតឆ្លើយ:

– នៅលើទូក អ៊ំពុគេថាម៉ីហួងគួនៅលើកំពូលភ្នំត្រចៀកខ្លាឃ្មុំ ។

រុនយូពោលដោយញាប់ញ័រ:

– ទេវតាមានភ្នែកទិព្វមែនទើបនាំផ្លូវយើងឲ្យរកឃើញវា ។ បងឈីង, មក!

ស៊ីឈីងងក់ក្បាល គោរពលាប៉ាយជីចាយភ្លាម ។ តាចាស់កំពុងតែសប្បាយទើបស្រែកឡូឡា:

– យី! ប្រញាប់ទៅណា? នៅលេងជុំគ្នាបួនដប់ថ្ងៃឬកន្លះខែសិន ។

– ទេ! លោកអ៊ំមិនទាន់ជ្រាបថាម៉ីហួងគួជាសត្រូវប្រចាំជីវិតប្តីខ្ញុំទេ, វាសម្លាប់កូនប្រុសខ្ញុំណា! ខ្ញុំស្វែងរកវាជាងដប់ឆ្នាំហើយ ទើបនឹងបានដំណឹងក្នុងពេលនេះឯង ។

ប៉ាយជីចាយទះភ្លៅផ្ទឹង:

– ស្ត្រីនោះសម្លាប់កូនប្រុសក្មួយឯងឬ? អស្ចារ្យមែន! រឿងក្មួយក៏ដូចរឿងអ៊ំដែរ ។ ទៅពួកយើង! មានកញ្ចាស់ទីងនិងម៉ឺរុនសាំងផង, ក្មួយត្រូវរកជំនួយខ្លះទើបឈ្នះវា ។

តាចាស់បានជួបជុំគ្រួសារវិញ គាត់សប្បាយរីករាយណាស់ ។ ទោះឲ្យគាត់ធ្វើអ្វីក៏គាត់មិនរុញរាដែរ ។ ប្ដីប្រពន្ធស៊ីឈីនថ្លែងអំណរគុណ ហើយចេញដំណើរភ្លាម ដោយមិនរង់ចាំពួកឥសីវត្តអាស្រមសាំងឈីនមកដល់ទេ ។ ស៊ីផានទៅតាមគេដែរ ។

គេនាំគ្នាចេញដំណើរតម្រង់ភ្នំត្រចៀកខ្លាឃ្មុំដែលមានបរិវេណរាប់សិបគីឡូម៉ែត្រ ។ គេដើរលើភ្នំពីរបីថ្ងៃឥតជួបមនុស្សម្នាក់សោះធ្វើឲ្យប៉ាយជីចាយតប់ប្រមល់ក្នុងចិត្តក្រៃលែង បន្ទោសស៊ីឈីនៈ

— ក្មួយស៊ីពីរនាក់ប្ដីប្រពន្ធមានយុទ្ធសិល្បៈគុនដាវពូកែប៉ុណ្ណឹងដែរ រក្សាកូនប្រុសមួយមិនគង់ហ្ន៎ ! ហើយម៉ុហ្វួនគូនោះមានគំនុំអ្វីជាមួយក្មួយបានជាលួចកូនទៅសម្លាប់ចោល ?

ស៊ីឈីនដកដង្ហើមវែង :

—នេះជាកម្មពៀរវេរារបស់ខ្ញុំទេ, សូមលោកអ៊ំកុំរំឭកវា ។

ស្រាប់តែវុនយូពោលថា :

—បងឈីននាំយើងឲ្យដើរខុសផ្លូវហើយដឹង ? បើបងមិនហ៊ានសម្លាប់គេសងសឹកឲ្យកូនផងទេ...

អ្នកស្រីពោលដល់នេះអួលបំពង់កហូរទឹកភ្នែករហាម ។ ប៉ាយជីចាយកើតការងឿងឆ្ងល់សួរទៀតថា :

ហេតុអីមិនហ៊ានសម្លាប់ ? អីយ៉ា ! ក្មួយប្រុស, ប្រហែលម៉ុហ្វួនគូស្អាតណាស់, ហើយក្មួយមានទាក់ទងជាមួយគេក្នុងផ្លូវម៉្យាងៗកាលពីដើមឬ ?

ស៊ីឈីនក្រហមមុខ :

— សូមលោកអ៊ំកុំមានប្រសាសន៍អ៊ីចឹង ។

ប៉ាយជីចាយសម្លក់ស៊ីឈីនពោលបន្ត :

—ច្បាស់ជាមានរឿងស្នេហាអីហើយ បានជាគេប្រច័ណ្ឌច្រណែនរហូតលួចកូនយកទៅសម្លាប់នោះៗ

វុនយូតបជំនួសស្វាមី :

— មិនមែនបងឈីនទាក់ទងនឹងគេមុនទេលោកអ៊ំ, គឺស្ត្រីនោះលបលួចស្រឡាញ់គាត់រហូតស្រោចកំហឹងលើក្មេងតូច , ហ៊ឺ ! កូនខ្ញុំក៏សត់ណាស់ ។

ពេលនេះស្រាប់តែស៊ីផានលាន់មាត់ :

—យី ! ម៉េចមកដល់ទីនេះ ?

មាណពបញ្ចេញទឹកមុខងឿងឆ្ងល់សម្រាលខ្លួនរត់សំដៅកំពូលភ្នំខាងឆ្វេងដៃ ។ នាយភ្ញាក់ផ្អើលឡើងដោយស្គាល់ទេសភាពព្រៃភ្នំនេះច្បាស់ណាស់ ។ លុះពិនិត្យមួយសន្ទុះទើបនឹកឃើញថាទីនេះជាលំនៅឋាននាយតាំងពីតូចនោះឯង ។ នាយរត់ទៅៗ...កាត់ព្រៃឫស្សី, ដល់ទីធ្លា. រួចដល់ខ្ទមស្លឹកមួយ ឮសូរឆ្កែព្រុសវូសៗ .នុះ ឆ្កែពណ៌លឿងមួយក្បាលរត់ចេញមក លោតស្គ្រប់នាយជាប់ ។ មាណពស្រវាឱបឆ្កែស្រែកហៅដោយរីករាយ:

- អាវ៉ូង, ឯងត្រឡប់មកពីកាលណា ? ឯណាម៉ែ ? ម៉ែអើយ, ម៉ែ ! .. ម៉ែ !

ពេលនោះឃើញមនុស្សបីនាក់ដើរចេញពីខ្ទមស្លឹកគឺទីងមិនញួសប្អូន, មីរ៉ុនសាំងនិងស្ត្រីម្នាក់ទៀត ដើរកណ្តាលមុខអាក្រក់ក្រៃលែង ជាម្តាយស៊ីផាន ។ មាណពឃើញស្ត្រីនោះភ្លាមពារអាវ៉ូងស្ទុះទៅស្រែកហៅម៉ែ ! ម៉ែ ! ស្ត្រីមុខអាក្រក់សួរសោះកក្រោះថា :

- ឯងទៅណា បាត់យូរម្ល៉េះ ?

ស៊ីផានឆ្លើយមិនទាន់ផងស្រាប់តែឮសម្លេងរ៉ុនយូស្រែកពីក្រោយ:

- មីហួនគូ ! ទោះឯងប៊ុនបន្ទំ យ៉ាងណាក៏មិនកំបាំងភ្នែកយើងដែរ ។ ឯងរត់ដល់ជើងមេឃក៏យើង...

ស៊ីផានភ្ញាក់ព្រឺក្បាលសំពោងងាកមកពោលទាំងតក់ស្លុត:

- លោកស្រីសុំច្រឡំហើយ ! នេះជាម្តាយខ្ញុំ មិនមែនសត្រូវសម្លាប់កូនលោកស្រីទេ !

ប្តីប្រពន្ធស៊ីឈើងឮមាណពហៅស្ត្រីមុខអាក្រក់ថាម៉ែក៏សួរបញ្ជាក់:

- គេជាម្តាយបង្កើតរបស់ឯងឬ ?

- បាទ, ខ្ញុំនៅជាមួយគាត់តាំងពីតូចមករហូតដល់ថ្ងៃមួយ, ម៉ែខ្ញុំទៅណាបាត់ ខ្ញុំចាំយូរពេក មិនឃើញគាត់ ទើបចុះទៅរកដល់វង្វេងផ្លូវ, បាត់ទាំងអាវ៉ូងរហូតមក ។ នេះជាឆ្កែខ្ញុំឈ្មោះអាវ៉ូង ។

នាយឱបរឹតអាវ៉ូងដោយក្តីសប្បាយរីករាយ ស៊ីឈើងងាកទៅស្ត្រីមុខអាក្រក់ពោលថា:

- ហួនគូ, នាងមានកូននឹងគេដែរ ម៉េចទៅចាប់កូនខ្ញុំមកសម្លាប់ចោលទៀត ។

សំនួរនេះមានន័យជូរចត់ណាស់, តែស្ត្រីមុខអាក្រក់ទទួលខ្លួនថាឈ្មោះមីហួនគូពោលយ៉ាងព្រងើយ :

- យើងចង់សម្លាប់អ្នកណាត្រូវសម្លាប់ឲ្យបាន, មិនបាច់ឯងសាកសួរទេ ។

ស៊ីផានសួរតិចៗដែរ :

–ម៉ែ, ម៉ែសម្លាប់កូនប្រុសលោកម្ចាស់ក្លូប៉ីស៊ីមែនឬ ? ហេតុអី ?

–ម៉ែចង់សម្លាប់កូនអ្នកណា ស្រេចនៅចិត្តម៉ែ, មិនបាច់រកហេតុផលទេកូន ។

វ៉ុនយូហូតដាវសន្សឹមៗពោលទៅកាន់ស្វាមី :

បងឈីង ខ្ញុំមិនឲ្យបងពិបាកដោយសាររឿងនេះទេ ។ បងឈរស្ងៀមចុះ, បើខ្ញុំសម្លាប់គេមិនបានបងក៏កុំបាច់ជួយ ។

ស៊ុឈីងជ្រួញចិញ្ចើមឈរទ្រឹងដោយការឈឺចាប់ ។ ប៉ាយជីតាយឲ្យយោបល់ :

– អីកញ្ចាស់ទីង យើងនិយាយគ្នាឲ្យហើយណា ! បើប្ដីប្រពន្ធឯងនៅស្ងៀមយើងក៏នៅស្ងៀមដែរ ។ ឲ្យតែឯងហ៊ានជួយកូនស្រី, ពួកយើងលែងឈរឱបដៃមើលហើយ ។

ទីងមិនហ្វូសប្អូនឆ្លើយ :

ល្អ ! ខាងណោះមានម្ដាយនិងកូន, ខាងណោះមានប្ដីប្រពន្ធ ឃើញថា ស្មើគ្នាល្អណាស់, ទុកឲ្យគេដោះស្រាយរឿងផ្ទាល់ខ្លួនគេចុះ ។

ត្បិតទីងមិនហ្វូសប្អូនធ្លាប់ប្រយុទ្ធជាមួយស៊ុផងនាប៉ុន្មានលើក ដឹងថាមាណពខ្លាំងពូកែណាស់ ទោះបីយ៉ាងណាក៏ហ្វូងគូមិនចាញ់ប្ដីប្រពន្ធស៊ុឈីងដែរ ។

វ៉ុនយូសួរមាណព : «ប្អូនប្រុសមិនឲ្យយើងសងសឹកមែនឬ » ។

– លោកស្រីស៊ុ, ខ្ញុំសុំ ...

នាយលុតជង្គង់សំពះអង្វរពេបក្បាលដល់ដី : សូមលោកស្រីកុំធ្វើបាបម៉ែខ្ញុំ ។

ម៉ីហ្វូងគូស្រែកសន្ធាប់ : ក្រោកឡើងអាក្អេឥតពូជ ! នរណាឲ្យឯងសំពះអង្វរស្រីចង្រៃនេះ ?

វ៉ុនយូភ្ញាក់ព្រើតសួរថា :

– ហេតុអីឯងហៅកូនរៀបហ្នឹង ? ស្រីឯងបង្កើតវាមកឬ ? អូយបងឈីង (គាត់ងាករកស្វាមី) ប្អូនប្រុសនេះមុខមាត់ដូចកូនយើណាស់, ក្រែងជាកូនបងនិងនាងនេះទេដឹង ?

ស៊ុឈីងប្រកែកភ្លាម : ទេៗ, គ្មានរឿងអាស្រូវដូច្នេះទេ ។

ប៉ាយជីតាយស្រាប់តែសើចក្អាកក្អាយ :

– កុំប្រកែកអីក្មួយអើយ, ពិតជាកូនក្មួយឯងនិងនាងហ្វូងគូហើយ ! ដល់គាត់ស្អប់ក្មួយឯងពេក ហៅវាថាក្អេឥតពូជទៅណា !

Khmer Story Lovers

វុនយូស៊ីរក់ទឹកភ្នែកបន្ទន់កាយដាក់ដាវថ្នាល់ដីពោលដោយស្រទន់ :

— សូមបងជួបជុំជាមួយគ្រួសារវិញចុះ , ខ្ញុំសុំ . . . លាហើយ ។

អ្នកស្រីក្រោកក្រេះបោះជំហានមួយៗ ដើរចេញទៅ, ស៊ីឈីងភ័យស្លន់ទាញដៃភរិយាឃាត់ជាប់ស្រែកគំហក :

— អូនយូ, បើនៅសង្ស័យរបៀបហ្នឹង, សូមអូនចាំមើលខ្ញុំសម្លាប់ស្រីចង្រៃនេះសំដែងទឹកចិត្តស្មោះត្រង់បង្ហាញឲ្យជាក់ស្ដែង ។

វុនយូពោលទាំងទឹកភ្នែក : មិនត្រឹមតែដូចកូនយីទេ, កូននេះដូចបងណាស់ដែរ ។

រំពេចនោះស៊ីឈីងហូតដាវខ្វាកចាក់ដើមទ្រូងហ្សួនគូ ។ ស្ដ្រីចំឡែកពើងទ្រូងចាំទទួលអាវុធឥតព្រិចភ្នែកសោះ, តែស៊ីផានលូកដៃផ្ទាត់ដាវស៊ីឈីងពុតឹង បាក់ជាពីរកំណាត់ភ្លាម ។

ម៉ីហ្សួនគូឆ្លាយសំណើចយ៉ាងឈឺចាប់ស្រែកសួរ : «ស៊ីឈីងចង់សម្លាប់យើងណាស់ទៅឬ?

—ហ្នឹងហើយ! ហ្សួនគូ! យើងប្រាប់នាងម្ដងទៀតចុះក្នុងបេះដូងយើងមានតែរូបវុនយូទេ, គ្មានកន្លែងដាក់នារីណាផ្សេងឡើយ. យើងស្រឡាញ់តែវុនយូរហូតគ្រាអវសាន បើនាងនៅស្រឡាញ់ខ្ញុំដែរបានសេចក្ដីថានាងធ្វើទុក្ខបុកម្នេញខ្ញុំរហូតផុតជីវិត ។ កាលពីម្ភៃប្លាយឆ្នាំមុនក៏ខ្ញុំបាននិយាយប្រាប់នាងរបៀបហ្នឹងដែរ, ចិត្តខ្ញុំមិនចេះកែប្រែទេ ។

ស៊ីឈីងបន្ទន់សម្លេងពោលបន្ត:

— ហ្សួនគូ , កូននាងធំប៉ុនកូនខ្ញុំហើយ, ហើយខ្លាំងពូកែណាស់ , តែប៉ុន្មានឆ្នាំទៀតគេលេចឈ្មោះបោះសំឡេងពេញពិភពគុនហើយ , ជៀវខ្ញុំចុះ ។ ឪពុកគេនៅឯណា ម៉េចនាងមិនប្រាប់ឲ្យគ្នាបានដឹងសប្បាយផង ?

ស៊ីផានអង្វរទៀត : «មែនហើយម៉ែ, ពុកខ្ញុំនៅឯណា, ឈ្មោះអី? សុំម៉ែប្រាប់ខ្ញុំផង, ហេតុអីម៉ែហៅខ្ញុំថាក្មេងឥតពូជខុសពីម្ដាយគេផងទាំងពួង ?»

ហ្សួនគូឆ្លាយសំណើចឈឺចាប់ខ្លោចផ្សា :

— ឪពុកឯងជាអ្នកណា , ក្នុងលោកនេះក្រៅពីម៉ែគ្មានអ្នកណាដឹងទេ !

ហ្សួនគូងាកទៅសួរស៊ីឈីងពោលយ៉ាងក្រៀមក្រំ :

— ស៊ីឈីង, យើងដឹងតាំងពីយូរមកហើយថាក្នុងបេះដូងឯងមានតែវុនយូម្នាក់គត់ ។ ព្រោះ

ហេតុហ្នឹងបានជាយើងបំផ្លាញមុខចោលណា៎ !

ស៊ុណប៉េងជណ្ដឹងសួរតថា: «ម៉េចអ៊ំធ្វើប៉ុណ្ណេះ » ។

–ហ៊ុះ ! ម៉េចមិនឲ្យយើងធ្វើ ? កាលពីដើមអ្នកណាល្អជាង, នុនយូ ឬហ្វុងគូ ?

ស៊ុឈីងក្ដាប់ដៃភរិយាយ៉ាងណែនតបវិញ : « ប្រហែលម្ភៃប៉ាយឆ្នាំមុន នាងជាបវរកញ្ញាដំល្បី នៃពិភពគុន, នុនយូមិនអាក្រក់ទេ តែមិនល្អដល់នាងឡើយ ។

ទីងមិនហ្លួសប្អូនស្រែកកាត់ :

–យី ! ស៊ីឈីងចំកួតយក៏ ! បើដឹងថាហ្វុងគូល្អឥតនរណាប្រៀបបានម៉េចឯងមិនស្រឡាញ់ ?

ស៊ីឈីងនៅស្ងៀមក្ដាប់ដៃនុនយូកាន់តែតឹងឡើង បញ្ជាក់សេចក្ដីស្នេហាស្មោះស្ម័គ្រឥតកែប្រែ ម៉ីហ្វុងគូសួរទៀត : «កាលពីដើមនរណាមានតម្រិះវិជ្ជាខ្ពស់ជាង, នុនយូ ឬហ្វុងគូ ? » ។

នាងចេះគុនប្រដាល់ប្រចាំត្រកូលសារនិងយុទ្ធសិល្បៈដទៃទៀត...

ទីងមិនហ្លួសប្អូនពោលកាត់ :

–ស្អីទៅហៅយុទ្ធសិល្បៈដទៃនោះ ? គ្រាន់តែស្នៀតគុនប្រចាំត្រកូលសារទីងមិនស្គាល់ដែរ ល្ងង់មែន !

–ហ្នឹងហើយ, កាលណោះនាងចេះយុទ្ធសិល្បពីរបែប, នុនយូមិនទាន់បានចូលជាសមាជិកអាស្រម សាំងឈីងផង, មិនអាចប្រៀបផ្ទឹមជាមួយនាងទេ ។

ម៉ីហ្វុងគូសួរថែម : «ចំណែកអក្សរសាស្ត្រវិញ, មួយណាពូកែជាង ?» ។

– ទុ ! នាងចេះតាក់តែងកំណាព្យនិងចម្រៀង, ប្ដីប្រពន្ធខ្ញុំសុំចាញ់ហើយ ។

ស៊ុផានដណ្ដឹងសួរក្នុងចិត្ត: «ម៉ែចេះដឹងច្រើនណាស់តើ, ម៉េចគាត់មិនបង្រៀនយើងផងហ្ន៎ ? ។

ម៉ីហ្វុងគូសួរត :

–ខាងវិជ្ជាមេផ្ទះដូចជាដេរប៉ាក់ធ្វើម្ហូបអាហារច្បាស់ជាអ្នកស្រីនុនស្ទាត់ជំនាញណាស់ ។

ស៊ុឈីងគ្រវីក្បាល :

–អូ ប្រពន្ធខ្ញុំឥតចេះដេរប៉ាក់ខោអាវទេ, រឿងម្ហូបវិញចៀនពងទាមួយមិនឆ្អិនផង, ធ្វើម្ដេចប្រៀបផ្ទឹមនឹងនារីប៉ុនប្រសប់ដូចនាងបាន ?

ម៉ីហ្វុងគូសង្ខាប់ :

– បើពិតដូចនេះមែន, ម៉េចឯងព្រងើយកន្តើយនឹងយើងម្ល៉េះ ? បើបាននៅជិតប្អូនរួមគ្រូ ឯង

Khmer Story Lovers



និយាយមិនចេះភោយមាត់សោះ ។ ហេតុអី ?...ហេតុអី ?...

សម្លេងគាត់ញ័រដោយការឈឺចាប់, សោកស្តាយនិងអស់សង្ឃឹម ។ ស៊ីឈីងពោលម្តង ១ :

- នាងមុី, នាងមានគំរិះវិជ្ជាជ្រៅជ្រះមានប្រាជ្ញាស្មារតីលើសខ្ញុំឆ្ងាយណាស់ ហេតុនេះហើយបានជាខ្ញុំខ្មាសនាងរាល់ពេលជួបមុខគ្នា ហើយខ្ញុំយល់ថារូបខ្ញុំមិនសក្តិសមរស់នៅជិតនាងទេ ។

មុីហួងគូឈរភ្លេចខ្លួនមួយសន្ទុះ ទើបស្រែកកាស រត់លៀនស្លេវចូលក្នុងខ្ទមស្លឹកបាត់ ។ មុីវ៉ុនសាំង និងចឹងមិនហួសបណ្តូរត់តាមក្រោយភ្លាម។ វ៉ុនយូផ្តេកក្បាលលើទ្រូងស្វាមីពោលយ៉ាងទន់ភ្លន់

- បងឈីង, នាងមុីកំសត់ណាស់ ។ គេបានសម្លាប់កូនយើងមែនតែ...គិតសព្វទៅនរណាសប្បាយជាងនរណា, នរណារស់នៅម្នាក់ឯងដោយក្រៀមក្រំ ? ល្ហើយ! មិនបាច់សងសឹកទេ, ត្រឡប់ទៅវិញ...

ស៊ីឈីងសួរបញ្ជាក់ : « មិនសងសឹកឲ្យកូនទេឬ ? » ។

-ចាស! ទោះសម្លាប់គេទៅក៏មិនបានកូនជានមកវិញដែរ

ខណៈនោះពួចឹងមិនហួសបណ្តូស្រែកខ្លាំង។·

-កូនហួង...ម៉េច...សម្លាប់ខ្លួនអីចឹង ? ហ៊ុ! ចាំពុកទៅសម្លាប់អាស៊ីឈីងសងសឹកវិញ!

ទាំងអស់គ្នាភ្ញាក់ក្រញាង ។ មុីវ៉ុនសាំងបីហួងគូចេញពីខ្ទមស្លឹកមក, ដៃរាវខាងឆ្វេងត្រូវម្ជូរដល់ស្នាបញ្ចេញសាច់សទ្រលុកនិងចំណុចក្រហមច្បាស់ក្រឡែតត្រង់ដើមដៃ (ចំណុចក្រហមជាសញ្ញាព្រហ្មចារីយ៍បរិសុទ្ធនៃស្រីក្រមុំ) ។ មុីវ៉ុនសាំងស្រែកជំទាល:

-ហួងគូខំថែរក្សាខ្លួនប្រាណស្អាតបរិសុទ្ធរហូតដល់ពេលនេះនៃ! អាឆ្កែឥតពូជមិនដឹងកូនរណាទេ!

ទាំងអស់គ្នាងាកមើលស៊ីផានដោយអាការៈសង្ស័យជាទីបំផុត : មីហួងគូនៅក្រមុំព្រហ្មចារីយ៍តើមាណពរូបនេះជាកូននរណា ? ហេតុអីហួងគូទទួលខ្លួនធ្វើម្តាយគេ ?

ស៊ីឈីងនិងវ៉ុនយូអរតើតនឹកថា: កាលមុីហួងគូចាប់កូនតូចទៅនោះ ច្បាស់ជាឥតសម្លាប់ចោលទេ ។ វីសាកសពទារកដែលនាងផ្ញើទៅវិញជាមួយដាវ មានស្នាមរបួសពេញមុខមើល លែងស្គាល់ទៅហើយ, អាចចាត់ទុកជាខ្មោចក្មេងណាផ្សេងបាន ។ ម្យ៉ាងទៀតបើមាណពមិនមែនកូនជានយើង, មុីហួងគូមិនស្ទុះបរហូតហៅឆ្កែឥតពូជទេ ។ វីមុខមាត់គេម្តេចក៏ដូចកូនយើម្ល៉េះ ? គេពិតជាកូនជានដែលយើងស្មានថាស្លាប់នោះហើយ ! ឱ ! កូនជានកំសត់ណាស់, អាណិតណាស់ !

រីឯមាណពរឹតតែរវើរវាយលើសអ្នកផងទៅទៀត ។ នាយឈរធ្មឹងសញ្ជឹងគិត:

-យើងជានរណា, ឪពុកមួយណា, ម្ដាយនៅឯណា ?

ម៉ីហ្សួងគួស្លាប់ទៅហើយ បាននរណាឆ្លើយសំនួរនេះ ។ មាណពត្រូវពិចារណាត្រាវជ្រាវខ្លួនឯង, រកនឹកខ្លួនឯងទាល់តែឃើញ ។

មួយស្របក់ធំនាយភ្ញាក់កំណើត , ដោះស្រាយអាថ៌កំបាំងស្មុគស្មាញបានទើបងើបមើលមុខប្ដីប្រពន្ធស៊ុឈីង ។ ខ្សែភ្នែកទាំងបីប៉ះគ្នាមានពន្លឺថ្លាលើងលោង. បីនាក់តេះតក្កា . . . រុនយូឱបស៊ុផងានទុទានទាំងស្អូលអាក់ថា: កូន... កូនជាន ...

មាណពហៅម៉ែ ! ម៉ែ ! ត្បិតនាយទើបនឹងយល់ថា វិក្កឥតពូជគ្មាននរណាក្រៅពីកូនស៊ុឈីង ដែលម៉ីហ្សួងគួចាប់យកទៅតាំងពីតូចនោះឡើយ ។

-៙ ចប់ ៙-

Khmer Story Lovers

ដំកល់ទុកតាមលេខ ៤២៥ ចុះថ្ងៃទី ២៣-៦-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់